# ប្រាសាទតោនៅសំបូរព្រៃគុក (តួប៉ម C1)

ក្រុមប្រាសាទតោ គឺជាក្រុមប្រាសាទស្ថិតនៅកណ្ដាល ចន្លោះក្រុមប្រាសាទសំបូរ និងក្រុមប្រាសាទយាយព័ន្ធនៃតំបន់ប្រាសាទសំបូរព្រៃគុក។ ក្រុមប្រាសាទតោ មានតួប៉មប្រាសាទសរុបចំនួន ៤៣ ហើយក្នុងនោះមានប្រាសាទនៅល្អទាំងស្រុងចំនួន ១ នៅល្អពាក់កណ្ដាលចំនួន ៦ និងស្ថិតនៅក្រោមពាក់កណ្ដាលចំនួន៣៦។ ក្រុមប្រាសាទនេះ បានហ៊ុមព័ទ្ធដោយកំពែងធ្វើពីថ្មបាយក្រៀមចំនួនពីរជាន់ ដែលកំពែងខាងក្រៅមានបណ្ដោយ ៣២៨ម៉ែត្រ ទទឹង ៣១០ម៉ែត្រ ដែលមានច្រកចូលនៅទិសខាងកើតនិងខាងលិច។ រីឯកំពែងខាងក្នុងវិញ មានប្រវែង១៧២ម៉ែត្រ ទទឹង១៦០ម៉ែត្រ ដែលមានច្រកចូលនៅស្របទិសដូចគ្នានឹងកំពែងខាងក្រៅ។ នៅទិសព្យាសានចន្លោះកំពែងខាងក្នុង និងខាងក្រៅ មានស្រះបុរាណមួយមានប្រវែងបណ្ដោយ ៤២,១០ម៉ែត្រ ទទឹង៣២,៤០ម៉ែត្រ ដែលជាស្រះមានបាត និងជញ្ជាំងតម្រៀបដោយថ្មបាយក្រៀមជុំវិញ។ នៅផ្នែកខាងត្បូងនៃស្រះទឹកនេះ គេតម្រៀបជាជណ្ដើរសម្រាប់ចុះធ្វើពិធីសាសនាផ្សេងៗនៅក្នុងស្រះ។ នៅច្រកចូលកំពែងខាងលិច មានផ្លូវភ្ជាប់សម្រាប់ចេញចូលទៅកាន់បរិវេណក្រុងព្យាសានបុរៈ។

ប្រាសាទភាគច្រើននៅក្រុមប្រាសាទតោ សាងឡើងអំពីឥដ្ឋ និងថ្មបាយក្រៀម ហើយមានគ្រឿងមានគ្រឿងលម្អស្ថាបត្យកម្មធ្វើអំពីថ្មភក់ ដែលមានអាយុកាលចាប់ពីវាំងស.វ.ទី៧-ចុងស.វ.ទី៨។ ប៉ុន្តែ នៅក្នុងក្រុមនេះពុំមាននៅសល់សិលាចារឹកឱ្យអ្នកស្រាវជ្រាវសិក្សាបានឡើយ។ ម្ល៉ោះហើយ ដើម្បីសិក្សាអំពីប្រាសាទនេះគេបានពឹងផ្អែកយ៉ាងសំខាន់លើការសិក្សាប្រៀបធៀបប្លង់ និងក្បាច់លម្អនៃប្រាសាទប៉ុណ្ណោះ។ តាមការសិក្សារបស់លោក Daniel Michon ក្រុមប្រាសាទតោសាងឡើងស្របជាមួយទ្រឹស្ដីនៃលទ្ធិព្រហ្មញ្ញសាសនា និកាយព្រះឥសូរ ដូចក្រុមប្រាសាទសំបូរ និងក្រុមប្រាសាទយាយព័ន្ធដែរ។ ដ្បិត លោកបានសិក្សាអំពីប្លង់ទូទៅ ដោយធៀបជាមួយប្លង់ក្រុមប្រាសាទផ្សេងទៀត និងធៀបជាមួយគម្ពីរព្រហ្មញ្ញសាសនា។[១] ក្នុងឆ្នាំ១៩១៣ លោក Henri Parmentier បានសិក្សា និងចុះបញ្ជីក្រុមប្រាសាទតោថា "ក្រុមប្រាសាទកណ្ដាល" តាងដោយអក្សរ C (Central) ដោយហេតុថាក្រុមនេះស្ថិតនៅកណ្ដាលក្រុមខាងជើងនិងខាងត្បូង។[២]

ប្រសិនយើងពិនិត្យទៅលើការរៀបចំប្លង់ជាទូទៅ នៃក្រុមប្រាសាទតោយើងឃើញថា នៅជ្រុងកំពែងទាំងពីរជាន់ គ្រប់ទិសទាំងអស់ គេសាងជាតួប៉មប្រាសាទដូចៗគ្នា តែសព្វថ្ងៃតួប៉មទាំងនោះ

---

[១] Michon 2008: 20-24.

[២] Parmentier 1913: 23.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

បានបាក់បែកអស់ហើយ។ ប៉ុន្តែច្រកទ្វារចូលគេមិនធ្វើជាបួនទិសដូចក្រុមប្រាសាទយាយព័ន្ធឡើយ ពោល គឺមានតែច្រកខាងកើតនិងខាងលិច។ ក្នុងបរិវេណកំពែងខាងក្រៅ ក្រៅពីស្រះទឹក យើងឃើញមានតួប៉មប្រាសាទចំនួន៨។ ក្នុងនោះនៅខាងកើត មានតួប៉មចំនួន ៥ ដែលតួប៉ម ៤ សាងអមច្រកទ្វារចូលជាពីរជាន់ និងតួប៉ម ១ទៀត សាងនៅជិតជ្រុងកំពែងទិសអាគ្នេយ៍។ ក្នុងចំណោមតួប៉មទាំង ៥ នៅខាងកើត មានតួប៉មពីរសាងឡើងអំពីថ្មបាយក្រៀម មានរាងទ្រវែង តែយើងមិនដឹងជាអ្វីឱ្យប្រាកដទេ។ ក្នុងបរិវេណកំពែងខាងក្រៅដដែល នៅខាងជើងមានតួប៉ម ២, ខាងលិចមានតួប៉ម ១។ ចំណែក បរិវេណកំពែងខាងក្នុងវិញ មានតួប៉មសំខាន់មួយនៅចំកណ្ដាល សព្វថ្ងៃអ្នកស្រុកហៅថា "ប្រាសាទតោ" ហើយមានតួប៉មចំនួន ៤ ទៀត សង់នៅអមច្រកចូលខាងលិច និងខាងកើត។ តើប្រាសាទតោ (តួប៉ម C1) មានលក្ខណៈបែបណាខ្លះ?

តួប៉មនេះ សង់ឡើងអំពីឥដ្ឋបូកកំបោរបាយអ (កំបោរបាយអសព្វថ្ងៃជ្រុះអស់ហើយ) រាងបួនជ្រុងទ្រវែង បែរមុខទៅទិសខាងកើត សង់នៅលើខឿនធ្វើអំពីឥដ្ឋ (រូបលេខ១-៣)។ ប្រាសាទនេះ មានកម្ពស់ ១៤ម៉ែត្រ ជញ្ជាំងកម្រាស់ ២,៥ម៉ែត្រ បណ្ដោយ ១៥,៥ ម៉ែត្រ និងទទឹង ១២,៤៤ ម៉ែត្រ។ នៅផ្នែកខាងក្នុងប្រាសាទ សិល្បកររៀបជាបន្ទប់សក្ការមានរាងបួនជ្រុងទ្រវែង លយចេញមកច្រកចូលខាងកើតបន្តិច។ ជញ្ជាំងខាងក្នុងលម្អដោយក្បាច់សសរផ្ដោបជ្រុង រៀបជារាងសាជីជ្រុង ដែលសព្វថ្ងៃយើងឃើញមានសេសសល់ស្នាមទឹកពណ៌ ដែលគេលាបជាប់នឹងជញ្ជាំង។ ផ្នែកខាងកើត គេរៀបជារាងសាជីជ្រុងដែលនៅខាងលើ ទ្រដោយថ្មភក់មួយដុំសម្រាប់សម្រាលទម្ងន់ប្រាសាទ ហើយនៅតាមក្បាលជញ្ជាំង មានថ្មភក់រាងដូចកំណាត់ឈើជ្រុងគេតម្រៀបជុំវិញប្រាសាទធ្វើជាពិតានឬទ្រមេពិតាន។ ផ្នែកដំបូលខាងក្នុង គេរៀបជាថ្នាក់ៗរាងកោងត្រង់ស្លួចចុងប៉ះគ្នានៅផ្នែកខាងលើដែលមានកំពូលធ្វើអំពីថ្មភក់តែសព្វថ្ងៃកំពូលប្រាសាទធ្វើអំពីថ្មភក់នេះបានជ្រុះធ្លាក់មកក្រោមអស់ហើយ។ សព្វថ្ងៃ នៅខាងក្នុងប្រាសាទមានសេសសល់បំណែកជើងទម្រខ្លះ តែយើងមិនដឹងប្រាសាទជាតួប៉មនេះតម្កល់អាទិទេពណាមួយនោះទេ។ ប៉ុន្តែ អ្នកស្រាវជ្រាវជាន់ថ្មីយល់ថា ជើងទម្រនេះអាចតម្កល់សិវលិង្គដូចក្រុមប្រាសាទផ្សេងៗដែរ។[៣]

នៅមុខខាងកើត គេរៀបក្បាលជណ្ដើរអមសងខាងខឿនយ៉ាងខ្ពស់ភ្ជាប់ដោយបដិមាតោមួយគូ កាំជណ្ដើរ ៧កាំ ទ្រនាប់ជណ្ដើរ ១។ ចម្លាក់តោនៅទីនេះមានចំនួនសរុប ៦ ពោល គឺគេដាក់នៅមុខទ្វារចូលទិសខាងកើត មុខទ្វារបញ្ឆោតទិសខាងជើង និងមុខទ្វារបញ្ឆោតទិសខាងត្បូង ប៉ុន្តែ

[៣]Michon, 2008: 20-24.

នៅខាងលិចពុំមាននោះឡើយ។ បដិមាតោចំនួន ៣ គេយកទៅរក្សាទុកនៅសារមន្ទីរខេត្ត តែបដិមាតោ១បាត់បង់ទៅហើយ។ អ្នកស្រាវជ្រាវប្រវត្តិសិល្បៈដ៏ល្បីល្បាញមួយរូប គឺលោក Jean Boisselier យល់ថា បដិមាតោនេះអាចសង់ឡើងពេលវេលាខុសគ្នាជាមួយប្រាសាទ (សាងក្រោយប្រាសាទ)។[៤] ចំណែកឯលោក Phillipe Stern យល់ថា បដិមាតោនេះមានលក្ខណៈស្រដៀងតោនៅប្រាសាទថ្មដាប់លើភ្នំគូលែន ហើយស្ថិតនៅក្នុងរចនាបថគូលែន ចុងស.វ.ទី៨។[៥] ចម្លាក់តោទាំងអស់មានមាត់បើកធំ ធ្មេញសំប៉ែតធំ ភ្នែកបើកសំឡឹងមើលទៅមុខ រោមរួញសំពោងធំជាងដងខ្លួន កន្ទុយដាក់សន្ធឹងរហូតដល់ក្បាល ជើងទាំងបួននៅនឹងថ្កល់ឥតចលនា ក្បាល និងដងខ្លួនមិនសមាមាត្រគ្នាទេ គឺក្បាលធំជាងដងខ្លួន តែសិល្បករឆ្លាក់យ៉ាងផ្ចិតផ្ចង់ (រូបលេខ២)។[៦]

ហោជាង មានរាងដូចក្រចកសេះដែលមានលម្អក្បាច់ផ្សេងៗ តែសព្វថ្ងៃរបេះក្បាច់អស់ហើយ។ នៅអមសងខាងទ្វារចូលនីមួយៗ និងនៅតាមជ្រុងជញ្ជាំងប្រាសាទមានលម្អជាក្បាច់សសរផ្តោប និងនៅតាមក្បាលជញ្ជាំងទំនងជា មានលម្អដោយក្បាច់ផ្សេងៗដូចតួប៉មដ៏ទៃទៀតដែរ តែបច្ចុប្បន្នបានរបេះជ្រុះធ្លាក់មកក្រោមអស់។ ចន្លោះសសរផ្តោបនីមួយៗនៅលើជញ្ជាំងប្រាសាទ មានលម្អចម្លាក់វិមានអណ្តែតក្នុងមួយទិសមានចំនួន២ (រូបលេខ៥-៦)។ ចម្លាក់វិមានអណ្តែតនីមួយៗគេលម្អជាបីថ្នាក់ ដែលថ្នាក់ខាងក្រោមមានបន្ទះថ្មកក់ស្តើងមួយទ្រពីក្រោម ជំនួសរូបចម្លាក់សត្វទេវកថាដូចគេធ្លាប់ឃើញនៅប្រាសាទដទៃទៀតនៅតំបន់សំបូរព្រៃគុក ហើយបង្ហាញពីការវិវត្តមួយបែបនៃចម្លាក់វិមានអណ្តែតនៅសម័យមុនអង្គរ។

ដោយឡែក ផ្តែរទ្វារតួប៉មនេះ មានគ្រប់ទិសទាំងបួន។ ផ្តែរទ្វារខាងកើតទំនងឆ្លាក់មិនទាន់ហើយនោះទេ ដែលមានក្បាច់បន្ទាត់ធ្នូរាងត្រង់ខាងចុងមានជាក្បាលមករបែរមុខចេញក្រៅឆ្លាក់មិនហើយ និងផ្នែកខាងក្រោមជារំយោលផ្កាឬកម្រងមាលា។ ផ្តែរទ្វារខាងជើងនិងខាងត្បូងមានលក្ខណៈដូចគ្នា ដោយនៅខាងចុងផ្តែរទាំងសងខាងលម្អជាសន្ទឹកឈើ ក្បាច់បន្ទាត់ធ្នូមានរាងត្រង់លម្អដោយសន្ទឹកឈើតម្រៀបគ្នាចំនួន៥ ហើយនៅខាងក្រោមមានលម្អជារំយោលផ្កា ឬកម្រងមាលា (រូបលេខ៧)។ លោក Boisselier, Jean យល់ថា ផ្តែរទ្វារខាងជើងនិងខាងត្បូង ស្ថិតនៅក្នុងចុងរចនាបថព្រៃក្មេង។[៧] ចំណែកផ្តែរទ្វារខាងលិចមានក្បាច់បន្ទាត់ធ្នូ មានរាងមូលដូចមែកឈើ

---

[៤] Boisselier 1966: 197.

[៥] Stern 1938: 141.

[៦] លាង ស៊ីណាំ ២០០៧: ៤៣។

[៧] Boisselier 1968: 101.

*ក្បួចជាកង់ៗដោយក្បាច់ផ្ការំដួលធ្លាក់រំយោលចុះមកក្រោម ដែលផ្នែកខាងចុងនៃបន្ទាត់ធ្នូមានរាង កោងវង់ចូលក្នុងដោយក្បាច់គួចខ្សែ ផ្នែកខាងលើនិងខាងក្រោមផ្តែរលម្អជាសន្ទឹកផ្កានិងរំយោល ផ្កាឬកម្រងមាលា* (*រូបលេខ៨*)*។ ផ្តែរខាងលិច មានក្បាច់លម្អជាទូទៅដូចផ្តែរនៅប្រាសាទវត្ត ប្រាសាទដែរ*[៨] *ហើយមានលក្ខណៈជិតចូលដល់រចនាបថគូលែន* (*ចុងស.វ.ទី៨*)*។*[៩]

*កន្លងមក ប្រាសាទតោ តួប៉ម* C1 *ធ្លាប់មានអ្នកសិក្សាស្រាវជ្រាវច្រើនជំនាន់មកហើយ និង បានផ្តល់នូវការសន្និដ្ឋានផ្សេងៗគ្នា។ ជាក់ស្តែង ក្នុងឆ្នាំ១៩៣០ លោក* Phillipe Stern *យល់ថា សំណង់ប្រាសាទតោ ស្ថិតនៅអន្តរកាលរវាងចុងរចនាបថកំពង់ព្រះ និងដើមរចនាបថគូលែន* (*ចុង ស.វ.ទី៨ ដើមស.វ.ទី៩*) *ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២។ ក្រោយមក លោក* Boisselier Jean *និង លោកស្រី* Bénisti Mirreille *សិក្សាបន្តយល់ថា ជាសំណង់នៅអន្តរកាលរចនាបថព្រៃក្មេង និង រចនាបថកំពង់ព្រះ* (*ចុងស.វ.ទី៧ ដើមស.វ.ទី៨*) *ទំនងចុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១។ ប្រសិន បើយកការស្នើឡើងរបស់អ្នកប្រាជ្ញទាំងបីមកពិចារណាឡើងវិញ យើងអាចសន្និដ្ឋានថា ប្រាសាទ តោទំនងចាប់ផ្តើមកសាងឡើងនៅចុងស.វ.ទី៧ រវាងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ និងបានសាង បដិតោបញ្ចប់នៅចុងស.វ.ទី៨ ក្នុងរវាងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ ឧទ្ទិសដល់ព្រហ្មញ្ញសាសនា និកាយព្រះឥសូរ។*

អរិយធម៌ខ្មែរ KHMER CIVILIZATION

[៨] Bénisti 1971: 111.

[៩] Boisselier 1968: 134.

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*





រូបលេខ១-២៖ ប្រាសាទតោ តួប៉ម C1 (មើលពីទិសខាងកើត និងទិសអាគ្នេយ៍)



រូបលេខ៣៖ ប្រាសាទតោ តួប៉ម C1 (មើលពីទិសអាគ្នេយ៍)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៤៖ បដិមាតោនៅប្រាសាទតោ តួប៉ម C1 (មុខខាងកើត)



រូបលេខ២៥-៦៖ ចម្លាក់វិមានអណ្តែតនៅប្រាសាទតោ តួប៉ម C1

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៧៖ ផ្តែរទ្វារបញ្ឆោតខាងជើងប្រាសាទតោ តួប៉ម C1



រូបលេខ៨៖ ផ្តែរទ្វារបញ្ឆោតខាងលិចប្រាសាទតោ តួប៉ម C1

អរិយធម៌ខ្មែរ
KHMER CIVILIZATION

## ឯកសារយោង


**លាង ស៊ីណាំ**

២០០៧, *ចម្លាក់តោក្នុងសិល្បៈខ្មែរ, ភ្នំពេញ*

**Bénisti, Mireille**

1971, “Recherches sur le premier art khmer, III. Aux confins des styles de Prei Kmeng et de Kampong Preah ”, *Arts Asiatiques*, Tome 23, Paris

**Boisselier, Jean**

- 1966, “*Asie du Sud-Est, Le Cambodge* ”, Tome I, Paris
- 1968“Les linteaux khmère du VIII[e] siècle, Nouvelles données sur le style de Kampong Preah ”, *Arlibus Asiae*, Tome XXX, Paris

**Daniel Michon**

2008, *Digital modeling of tangible and intangible cultural heritage of temples anlong the pacific rim, the Śaivite temples of Sambor Prei Kuk, Cambodia*, Claremont Mckenna College, June 1, 2008

**Parmentier, Henri**

1913, “Complément à l’Inventaire descriptif des monuments du Cambodge”, *BEFEO,* Tome 13, Paris